**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**Council for the Development of Cambodia**

**ព្រះរាជាណាចក្រកម្ពុជា**
**Kingdom of Cambodia**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Nation-Religion-King**

*ថ្ងៃពុធ ១១កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៥១ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ៦០៨លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីដោយគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែសីហា ឆ្នាំ២០២៥

ក្នុងខែសីហា ឆ្នាំ២០២៥ គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានសម្រេចចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន**៥១គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ**៦០៨លានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានប្រមាណ**២៧ពាន់កន្លែង**។ ក្នុងចំណោមគម្រោងវិនិយោគសរុប គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ៣៥គម្រោង និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១៦គម្រោង។ ក្នុងរយៈពេល៨ខែនៃឆ្នាំ២០២៥នេះ គ.វ.ក. បានសម្រេចចុះបញ្ជីគម្រោងវិនិយោគចំនួន **៤៩១គម្រោង** ក្នុងទំហំទុនវិនិយោគសរុបប្រមាណ **៧,២**ប៊ីលានដុល្លារអាម៉េរិក គឺគម្រោងវិនិយោគមានការកើនឡើងចំនួន **២០៤គម្រោង** ស្មើនឹងប្រមាណ **៧១%** ខណៈទុនវិនិយោគមានការកើនឡើងប្រមាណ **២,៥**ប៊ីលានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ **៥០%** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ជាការកត់សម្គាល់ បើប្រៀបធៀបនឹងគម្រោងវិនិយោគដែលត្រូវបានចុះបញ្ជីក្នុងឆ្នាំ២០២៤ ដែលមានត្រឹមតែ **៤១៤គម្រោង** ក្នុងរយៈពេល៨ខែនេះ គ.វ.ក. បានចុះបញ្ជីគម្រោងវិនិយោគលើសការចុះបញ្ជីគម្រោងវិនិយោគពេញមួយឆ្នាំ២០២៤ រហូតដល់ទៅ **៧៧គម្រោង**។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែសីហា ឆ្នាំ២០២៥ មានដូចខាងក្រោម៖

### ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

| កសិកម្ម និងកសិ-ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រកែច្នៃផ្លែឈើ**<br>- **ទីតាំង៖** ស្រុករតនមណ្ឌល ខេត្តបាត់ដំបង<br>- **ទំហំទុនវិនិយោគប្រមាណ៖** ២៧លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ១.១៦០កន្លែង។ |
|---|---|

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ**<br>- **ទីតាំង៖** ស្រុកមេមត់ ខេត្តត្បូងឃ្មុំ<br>- **ទំហំទុនវិនិយោគប្រមាណ៖** ៨,៧លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ១៤០កន្លែង។ |

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតដែកគ្រោងសំណង់គ្រប់ប្រភេទ**<br>- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ឈីលូ ជាន ពុ ចាយ ស្ថិតនៅខេត្តស្វាយរៀង<br>- **ទំហំទុនវិនិយោគប្រមាណ៖** ១៧លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ៣៦៣កន្លែង។ |
| ហេដ្ឋារចនាសម្ព័ន្ធ | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតទឹកស្អាត សម្អាតទឹក និងផ្គត់ផ្គង់អគ្គិសនី**<br>- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ខេមបូឌាន ចេជាង ហ្គ័រជី ស្ថិតនៅខេត្តព្រះសីហនុ<br>- **ទំហំទុនវិនិយោគប្រមាណ៖** ១១លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ៩២កន្លែង។ |
| ទេសចរណ៍ | **គម្រោងវិនិយោគសាងសង់ និងអាជីវកម្មសណ្ឋាគារលំដាប់ផ្កាយ៤ ចំនួន១០០បន្ទប់**<br>- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ស្វាយរៀង ហ្គីហ្គា វីសស៍ ស្ថិតនៅខេត្តស្វាយរៀង<br>- **ទំហំទុនវិនិយោគប្រមាណ៖** ៨លានដុល្លារអាម៉េរិក<br>- **ការបង្កើតការងារ៖** ២០១កន្លែង។ |

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែសីហា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៥១** (១៦ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៦០៨** លាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~២៧ពាន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)



**១៤លាន** កសិកម្ម និងកសិ-ឧស្សាហកម្ម

**២៧៣លាន** វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

**៨លាន** វិស័យទេសចរណ៍

**៣១៣លាន** វិស័យឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. កម្ពុជា | ៤៥,៤៨% |
| ២. ចិន | ៤៣,៥៧% |
| ៣. សិង្ហបុរី | ៥,០៦% |
| ៤. អង់គ្លេស | ២,៦០% |
| ៥. កោះ Cayman | ១,៧៤% |
| ៦. កោះ British Virgin | ០,៨៥% |
| ៧. ជប៉ុន | ០,៧០% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ១១+
- ៦-១០
- ១-៥
- មិនមាន

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគចាប់ពី ខែមករា ដល់ខែសីហា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៩៩១** (១៩១ គម្រោង ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៧,២** ប៊ីលាន ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៣៥០៣ន់** កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)




## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. ចិន | ៥២,៨២% |
| ២. កម្ពុជា | ៣១,២៦% |
| ៣. សិង្ហបុរី | ៦,៩៤% |
| ៤. វៀតណាម | ៥,៤៥% |
| ៥. កោះ British Virgin | ០,៨៩% |
| ៦. អង់គ្លេស | ០,៦៧% |
| ៧. កោះ Cayman | ០,៥៥% |
| ៨. Burmeda | ០,៣៥% |
| ៩. សហរដ្ឋអាម៉េរិក | ០,២៩% |
| ១០. កោះ Samoa | ០,២៧% |

## របាយគម្រោងវិនិយោគនៅតាមបណ្ដារាជធានី-ខេត្ត

